**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមហាផ្ទៃ**

**អគ្គនាយកដ្ឋានរដ្ឋបាល**

លេខ : ៣៤២៩...រ.ដ.ប

ថ្ងៃអង្គារ ៦កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨

# ជម្រាបជូន

**ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ** : ស្ដីពីអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឆ្នាំ២០១៨ លើជំនាញ "វិស័យអភិបាលកិច្ច" នៃកម្មវិធីអាហារូបករណ៍ KOICA របស់សាធារណៈរដ្ឋកូរ៉េ។

**យោង** : លិខិតលេខ KOICA-Cambodia-2018-285 ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ(KOICA)។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបថា ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) បានផ្ដល់ឱកាសឱ្យមានការប្រឡងប្រជែងអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឆ្នាំ២០១៨ លើជំនាញ "វិស័យអភិបាលកិច្ច" នៅតាមសាកលវិទ្យាល័យដែលជាដៃគូរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) នៅសាធារណរដ្ឋកូរ៉េ។ អាហារូបករណ៍នេះមានគោលបំណងដើម្បីបង្កើនចំណេះដឹង និងជំនាញក្នុងវិស័យអភិបាលកិច្ចជូនដល់មន្ត្រីរាជការកម្ពុជា ជាពិសេសមន្ត្រីរាជការក្រសួងមហាផ្ទៃ។ រាល់ការចំណាយលើថ្លៃធ្វើដំណើរ ថ្លៃសិក្សា ការស្នាក់នៅ ធានារ៉ាប់រងសុខភាព និងប្រាក់ឧបត្ថម្ភជាបន្ទុករបស់ KOICA។

សម្រាប់លក្ខខណ្ឌជ្រើសរើស និងព័ត៌មានលម្អិតផ្សេងៗមានដូចខាងក្រោម ៖

## I. លក្ខណសម្បត្តិដើម្បីដាក់ពាក្យសុំអាហារូបករណ៍

- មានសញ្ជាតិខ្មែរ
- មានបរិញ្ញាបត្រ
- ជាមន្ត្រីរាជការបម្រើការនៅក្រសួងមហាផ្ទៃ (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ)។

## II. កាលបរិច្ឆេទឈប់ទទួលពាក្យ

អាហារូបករណ៍នេះនឹងផុតកំណត់ទទួលពាក្យនៅថ្ងៃទី**១៦ ខែមីនា ឆ្នាំ២០១៨**។ សម្រាប់ព័ត៌មានលម្អិតសូមចូលទៅកាន់គេហទំព័រ http://www.koicacambodia.org/scholarship/ ឬតាមរយៈលេខទូរស័ព្ទ: ០២៣ ៩៦៤ ១៥០/១/៣ ឬតាមរយៈអ៊ីម៉ែល koicascholar@gmail.com។

សូមជូនភ្ជាប់មកជាមួយនូវបញ្ជីកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ** មេត្តាជ្រាប និងចាត់ចែងផ្សព្វផ្សាយដល់មន្ត្រីរាជការក្រោមឱវាទឱ្យបានទូលំទូលាយតាមការគួរ។

សូម **ឯកឧត្តម លោកជំទាវ** មេត្តាទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**អគ្គនាយក**

ប្រាក់ សំអឿន

<u>សូមទំនាក់ទំនង៖</u>

- លោក ងួន គីមសេង
- ទូរស័ព្ទលេខ: ០១១ ៣២២ ២២៧